ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ១១០/២៥ គ.ជ.ប.ជ

# របាយការណ៍
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# ប្រចាំខែឧសភា និងទិសដៅខែមិថុនា ឆ្នាំ២០២៥

## I. ស្ថានភាពទូទៅ

ពិភពលោក កំពុងតែប្រឈមដោះស្រាយវិបត្តិសេដ្ឋកិច្ចជាសាកល ផលប៉ះពាល់នៃគ្រោះធម្មជាតិ ដែលកើតឡើងដោយបម្រែបម្រួលអាកាសធាតុ និងសង្គ្រាមប្រដាប់អាវុធដ៏រ៉ាំរ៉ៃ ដែលជំរុញឱ្យមនុស្សរាប់រយលាននាក់បង្ខំចិត្តចាកចេញពីផ្ទះសម្បែង ឬទីតាំងដែលខ្លួនរស់នៅ ហើយធ្វើទេសន្តប្រវេសន៍ដោយគ្មានការត្រៀមទុក ដែលក្លាយជាចលនាលំហូរពលករដែលគ្មានឯកសារ ខ្វះការគ្រប់គ្រង ដែលប្រឈមយ៉ាងខ្លាំងទៅនឹងកង្វះសុវត្ថិភាព អំពើរំលោភបំពាន និងការកេងប្រវ័ញ្ចជាច្រើនរូបភាព។

ការផ្សព្វផ្សាយយ៉ាងទូលំទូលាយរបស់បណ្តាញសារព័ត៌មាននានា ទាំងពិត ទាំងមិនពិត អំពីបទល្មើសជួញដូរមនុស្សនៅកម្ពុជា ព្រមទាំងការចាទប្រកាន់ពីបណ្តាប្រទេស ដែលមានពលរដ្ឋមកប្រព្រឹត្តបទល្មើស ឬមករងគ្រោះនៅកម្ពុជា បានធ្វើឱ្យមានការភ័ន្តច្រឡំ និងវាយតម្លៃជាអវិជ្ជមានលើស្ថានភាពសន្តិសុខនៅកម្ពុជា ដែលនាំឱ្យមានភាពរាំងស្ទះដល់ដំណើរការនៃចរន្តសេដ្ឋកិច្ចជាតិ និងប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋ។

ការផ្សព្វផ្សាយអំពីឱកាសការងារ និងការជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស ទាំងតាមប្រព័ន្ធផ្លូវការ ទាំងតាមបណ្តាញសង្គម និងមួយចំនួនធំជាការអូសទាញរបស់បណ្តាញជនល្មើស បានក្លាយជាកត្តាជំរុញ និងទាក់ទាញប្រជាពលរដ្ឋក្នុងតំបន់ និងពីបណ្តាប្រទេសនានាក្នុងពិភពលោក ក៏ដូចជាប្រជាជនកម្ពុជា ដែលពេញវ័យការងារឱ្យចាប់អារម្មណ៍ និងសម្រេចចិត្តយ៉ាងឆាប់រហ័ស និងផុលផុស ក្នុងការធ្វើចំណាកស្រុក ឬធ្វើទេសន្តប្រវេសន៍ទៅរកការងារ ដែលមានបៀវត្សរ៍ខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពឆបោក។ ចំនួនដ៏ច្រើនលើសលប់នៃប្រជាជនពេញវ័យការងារបានធ្វើចំណាកស្រុក មានរហូតដល់ជាងមួយលាននាក់ បាននិងកំពុងនៅធ្វើការងាររហូតដល់ប្រមាណ ១.៦លាននាក់ នៅក្រៅប្រទេស ដែលស្មើនឹងជិត២០ភាគរយ នៃប្រជាពលរដ្ឋវ័យ ពី១៥ឆ្នាំ ទៅ ៦០ឆ្នាំ និងអត្រាដ៏ខ្ពស់នៃការបោះបង់ការសិក្សាក្នុងកម្រិតមធ្យមសិក្សា បានប៉ះពាល់ទៅនឹងកង្វះធនធានពលកម្ម សម្រាប់ទទួលយកការងារដែលត្រូវបានបង្កើតឡើងក្នុងស្រុក តាមរយៈការវិនិយោគលើវិស័យឧស្សាហកម្ម និងសហគ្រាសធំៗ ដែលរាជរដ្ឋាភិបាលបាននិងកំពុងទាក់ទាញការចាប់អារម្មណ៍ពីអន្តរជាតិ។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ បានចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀត រួមទាំងផលប៉ះពាល់នៃគ្រឿងញៀន គ្រឿងស្រវឹង គ្រោះថ្នាក់ចរាចរណ៍ និងបានដាក់ចេញនូវយុទ្ធសាស្ត្រឆ្លើយតបកាន់តែមានប្រសិទ្ធភាព ដោយខិតខំជំរុញសកម្មភាពឥតឈប់ឈរ ដើម្បីការពារសុវត្ថិភាព និងសន្តិសុខមនុស្ស ក៏ដូចជាសន្តិសុខជាតិទាំងមូល ដើម្បីទ្រទ្រង់ដំណើរការអភិវឌ្ឍន៍គ្រប់វិស័យ។

នៅក្នុងខែឧសភានេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរាជធានី-ខេត្ត ក្នុងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត ដោយមានការចូលរួមគាំទ្រ និងសហការពីអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានធ្វើសកម្មភាពប្រតិបត្តិការយ៉ាងសកម្ម តាមយុទ្ធសាស្ត្រទាំងបួន នៃផែនការយុទ្ធសាស្ត្រជាតិដោយប្រឈមនឹងស្ថានភាពប្រែប្រួលឥតឈប់ឈរនៃបទល្មើស។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចសហប្រតិបត្តិការ

#### ក.១. កិច្ចសហប្រតិបត្តិការ

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចុះអនុស្សរណៈនៃការយោគយល់ជាមួយអង្គការ ការីតាស់ស្វីស ស្តីពីសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទម្រង់ផ្សេងទៀត នៃការកេងប្រវ័ញ្ចក្នុងការធ្វើចំណាកស្រុក។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់

ក្រុមការងារបង្ការ ទប់ស្កាត់ នៃ គ.ជ.ប.ជ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយតាមរយៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" វេទិកាសាធារណៈ និងការបញ្ជ្រាបការផ្សព្វផ្សាយតាមកម្មវិធីផ្សេងៗ សរុបចំនួន **១៥.៩០៩**លើក មានអ្នកចូលរួមសរុបចំនួន ៨៧០.៤៣៦នាក់ ក្នុងនោះស្ត្រី ៤៧៧.៧៥៣នាក់ (ប្រៀបធៀបនឹងខែមេសា មានចំនួន ១.០១១.៨២២នាក់) គឺមានការថយចុះប្រមាណ **១៦,២៤%** ដូចមានក្នុងតារាងខាងក្រោម៖

*តារាងទិន្នន័យសរុបការផ្សព្វផ្សាយដោយផ្ទាល់*

| ល.រ | សកម្មភាពផ្សព្វផ្សាយ | ចំនួនដង/លើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ០១ | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព និងវេទិកាសាធារណៈ | ១៤.៤៣៤លើក | ៨២២.៩៦១នាក់ | ៤៥៤.៩៤៤នាក់ |
| ០២ | កម្មវិធីផ្សេងៗ | ១.៤៧៥លើក | ៤៧.៤៧៥នាក់ | ២២.៨០៩នាក់ |
| | សរុប | ១៥.៩០៩លើក | ៨៧០.៤៣៦នាក់ | ៤៧៧.៧៥៣នាក់ |

*(សម្គាល់៖ ចំនួននេះមិនគិតអ្នកដែលបានទទួលព័ត៌មានតាមរយៈការចែកខិត្តប័ណ្ណ បណ្តាញសង្គម ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិកផ្សេងទៀតឡើយ)*

❖ **ការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | ៧៦ | ១៥.៧៣៣ | ៨.២៩៤ | ៤៥ | ១.៤១៩ | ៧.៣៣៩ |
| ២ | កណ្តាល | ១៥៨ | ៩៨០២ | ៤៣៨៨ | | | |
| ៣ | បាត់ដំបង | ៩៨៥ | ៥០.៤៣៤ | ២៧.៥០៥ | ៧៧២ | ២២.៤៩១ | ១៥.៣៤៨ |
| ៤ | ពោធិ៍សាត់ | | | | | | |
| ៥ | សៀមរាប | ៧៩៣ | ៤៧.៥៩០ | ២៨.៩៥១ | ៦៥៥ | ២៤.៨៣០ | ១៥.១៩៨ |
| ៦ | កំពង់ឆ្នាំង | ៧០០ | ២៣.៦២១ | ១២.៩៥៣ | ៣៧២ | ១២.៤៩៧ | ៦.៨២៤ |
| ៧ | កំពង់ចាម | ១.៦៨៣ | ៩៣.០៨៧ | ៤៨.៥៥៣ | ០៥ | ២០១ | ១៨០ |
| ៨ | ព្រះសីហនុ | ១៣០ | ៣.៧១៩ | ១.៨១៣ | ៣៧ | ១.២៥២ | ៦៦៨ |
| ៩ | ព្រះវិហារ | ១២ | ៥៧៨ | ២៨៦ | | | |
| ១០ | ស្វាយរៀង | ៣៩៩ | ១៧.៥៨៦ | ១២.០៤០ | ៥០០ | ១៨.៩០៥ | ១១.០៦៥ |
| ១១ | ប៉ៃលិន | ០២ | ៧៩ | ៣៣ | ១០៨ | ៤.១៣៨ | ២.០៨៩ |
| ១២ | កោះកុង | ៩៨១ | ១៧.១៨៩ | ៧.៦៨០ | ៣៥៥ | ៥.៩៩៤ | ២.៨៦៦ |
| ១៣ | កំពត | | | | ២៧ | ៤.៣៨១ | ២.៣១០ |
| ១៤ | កំពង់ធំ | ១.០៩៨ | ២៥២.៦៩៥ | ១៣២.៣៩៧ | ២៥៩ | ១១.៥០៨ | ៦.០៥៨ |
| ១៥ | តាកែវ | ១៨ | ២៩៨ | ១៣៧ | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៦ | ក្រចេះ | ៦២ | ១.៧៣២ | ១.០៤៤ | | | |
| ១៧ | កែប | ៥៦ | ៨.២៨០ | ៣.៧៨៥ | ១២២ | ៤.៨១២ | ២.៧៤៩ |
| ១៨ | កំពង់ស្ពឺ | ៣០៧ | ១៧.០០៧ | ៩.៥៩៥ | ៦៦ | ២.៨៩០ | ១.៥៥៦ |
| ១៩ | ស្ទឹងត្រែង | ២១១ | ១៣.៥៦៣ | ៧.១៣៥ | ១៦៣ | ៥.៩៤៣ | ៣.៤៩០ |
| ២០ | រតនគិរី | | | | | | |
| ២១ | ព្រៃវែង | ៩៥០ | ៦៨.៩៦៣ | ៣៨.០១៥ | ៦៤៣ | ២១.០៩៦ | ១១.៣៦០ |
| ២២ | ត្បូងឃ្មុំ | ៥៤ | ៤.០១៧ | ២.០៨០ | ១១៣ | ២.៩៥៣ | ១.២៦១ |
| ២៣ | បន្ទាយមានជ័យ | ៩៥៨ | ១៤.០៥២ | ៨.៣៤៩ | ២៧៤ | ៦.៤៩៩ | ៣.៩១៣ |
| ២៤ | ឧត្តរមានជ័យ | ១៤៦ | ៦.៦៧៧ | ៣.៦៩១ | ១៨ | ៦៧៤ | ៤០៥ |
| ២៥ | មណ្ឌលគិរី | ១១៣ | ៣.៣៦១ | ១.៣៣១ | ០៨ | ៤១៥ | ២១០ |
| សរុប រាជធានី-ខេត្ត | | ៩.៨៩២លើក | ៦៧០.០៦៣នាក់ | ៣៦០.០៥៥នាក់ | ៤.៥៤២លើក | ១៥២.៨៩៨នាក់ | ៩៤.៨៨៩នាក់ |
| សរុបរួម | | ១៤.៤៣៤លើក | | ៨២២.៩៦១នាក់ | | ៤៥៤.៩៤៤នាក់ | |

❖ **ការបញ្ជ្រាបការយល់ដឹងតាមរយៈកម្មវិធីផ្សេងៗ**

| ល.រ | រាជធានី-ខេត្ត អង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ខេត្តកណ្ដាល | ០៨ | ១០.៧១០ | ២២៧ |
| ២ | ខេត្តបាត់ដំបង | ០៨ | ៥.១៨៧ | ២.៤១៥ |
| ៣ | ខេត្តប៉ៃលិន | ០២ | ៣៤៤ | ១៧២ |
| ៤ | ខេត្តសៀមរាប | ១.០៩៩ | ៧.០១៩ | ៥.៥៨១ |
| ៥ | ខេត្តកំពង់ឆ្នាំង | ០៧ | ១៥៥ | ១៨ |
| ៦ | ខេត្តកំពង់ចាម | ០៥ | ១៤៣ | ៨៤ |
| ៧ | ខេត្តព្រះវិហារ | ០១ | ៤០០ | ២២៤ |
| ៨ | ខេត្តព្រៃវែង | ០១ | ២.៣២៤ | ២.០៨៩ |
| ៩ | ខេត្តត្បូងឃ្មុំ | ០៣ | ១.៦២៨ | ៥១៧ |
| ១០ | ខេត្តឧត្តរមានជ័យ | ១៦៧ | ៦.៧៧០ | ៣.៧៨៤ |
| ១១ | ខេត្តក្រចេះ | ០១ | ២៥០ | ១០៥ |
| ១២ | ខេត្តបន្ទាយមានជ័យ | ៩៨ | ៥.៤៨៨ | ២.៩៥៥ |
| ១៣ | ខេត្តកំពង់ធំ | ១១ | ២.៥១០ | ១.៥២១ |
| ១៤ | ខេត្តមណ្ឌលគិរី | ០១ | ៥១០ | ១៧៤ |
| ១៥ | អង្គការ Friend Insertional ( សៀមរាប ) | ០៤ | ៤.១៦៥ | ២.៤៥៧ |
| ១៦ | អង្គការមូលនិធិA21(សៀមរាប ) | ០១ | ២៣ | ១៣ |
| ១៧ | អង្គការសាម៉ារីតាន់កឹស( បាត់ដំបង ) | ៥២ | ៤១៧ | ២០៥ |
| ១៨ | អង្គការសាម៉ារីតាន់កឹស( បន្ទាយមានជ័យ ) | ០២ | ៥៥ | ៣៧ |
| ១៩ | អង្គការដំណក់ទឹក( បន្ទាយមានជ័យ ) | ០៣ | ២០២ | ១១៨ |
| សរុប | | ១.៤៧៤លើក | ៤៧.៣០០នាក់ | ២២.៦៩៦នាក់ |

## ខ.២. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់

❖ **ការផលិត និងចែកផ្សាយសម្ភារផ្ដល់ព័ត៌មាន និងអប់រំ** (IEC = Information Education Communication Materials)

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត | សកម្មភាព និងឧបករណ៍ផ្សព្វផ្សាយ | ចំនួនលើក | ចំនួនឧបករណ៍ | ចំនួនអ្នកទទួលបាន | ចំនួនស្ត្រី |
|---|---|---|---|---|---|---|
| ១ | សៀមរាប | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | ៨.៧៩៦ប័ណ្ណ | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | បន្ទាយមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ<br>-លេខទូរស័ព្ទហតឡាញបន្ទាន់ | ០៣ | ០៣ប័ណ្ណ | ១.៥១៨នាក់<br>២០២នាក់ | ៦០៨នាក់<br>១១៨នាក់ |
| ៣ | បាត់ដំបង | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | ១.១៧៤ប័ណ្ណ | | |
| ៤ | ព្រះវិហារ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ០៧ | ០៧ប័ណ្ណ | ៤៣៦នាក់ | ១១២នាក់ |
| ៥ | ឧត្តរមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | ១.០៧៥ប័ណ្ណ | | |
| សរុបផ្សព្វផ្សាយ១០លើក មានខិត្តប័ណ្ណ១១.០៥៥សន្លឹក, អ្នកទទួលបាន២.១៥៦នាក់ (ស្ត្រី៨៣៨នាក់) | | | | | | |

❖ **ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត | បណ្តាញផ្សព្វផ្សាយ | ចំនួនលើក/ដង/ស្ពត | ចំនួនអ្នកទស្សនា/ស្តាប់/អាន/Views |
|---|---|---|---|---|
| ១ | សៀមរាប | -វិទ្យុជាតិ | ២០៤ | |
| ២ | កំពង់ចាម | -វិទ្យុជាតិ | ១៥០ | |
| ៣ | ព្រៃវែង | -វិទ្យុជាតិ | ៥០ | |
| ៤ | ត្បូងឃ្មុំ | -វិទ្យុជាតិ | ៣២ | |
| ៥ | បន្ទាយមានជ័យ | -វិទ្យុជាតិ | ១៦ | |
| ៦ | ប៉ៃលិន | -វិទ្យុជាតិ | ៤៩៦ | |
| សរុប | | | ៩៤៨ លើក | |

❖ **ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ នៅតាមស្ថានីយវិទ្យុ និងទូរទស្សន៍**

▪ **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានផ្តល់កិច្ចសម្ភាសន៍ ដល់គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ ដើម្បីផលិតវីដេអូអប់រំផ្សព្វផ្សាយ ស្តីពីការរួមគ្នាក្នុងការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។

- លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៊ុណ្ណ សំខាន់ បានផ្តល់បទសម្ភាសន៍ជូនទូរទស្សន៍បាយ័ន ស្តីពីការយល់ដឹងអំពីសុវត្ថិភាព និងការការពារខ្លួនពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការឆបោក និងការរំលោភបំពានតាមប្រព័ន្ធអនឡាញ ដើម្បីផ្សព្វផ្សាយជាសារអប់រំ នាឱកាសពិធីអបអរសាទរខួបអនុស្សាវរីយ៍ លើកទី៨០ ថ្ងៃកំណើតនគរបាលជាតិកម្ពុជា ១៦ ឧសភា ២០២៥។

▪ **ខេត្តសៀមរាប៖** អធិការនៃអធិការដ្ឋានស្រុកស្រីស្នំ ស្រុកជីក្រែង ក្រុងសៀមរាប បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិវិទ្យុជាតិនគរភ្នំ ស្តីពីវឌ្ឍនភាព នៃការអនុវត្តគោលនយោបាយភូមិ ឃុំ/សង្កាត់ មានសុវត្ថិភាព។

## ខ.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ខ.៣.១. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានសម្ភាសន៍ជនបរទេស ដែលមកដាក់ពាក្យសុំចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ តាមផ្លូវច្បាប់ សរុបចំនួន **១៦០**នាក់ (ស្រី ០៩នាក់) មាន១២សញ្ជាតិ និងបានវាយតម្លៃបញ្ជូនទៅក្រុមការងារចម្រុះច្រកចេញ-ចូលតែមួយចំនួន ៣៨៣នាក់ (ស្រី ២០នាក)។ ក្នុងនោះមាន៖

| | | |
|---|---|---|
| ស្រីបរទេសជាមួយបុរសខ្មែរ | ០៩នាក់ | ចិន៩៤នាក់ កូរ៉េខាងត្បូង ៣២នាក់(ស្រី០៣នាក់) អាម៉េរិក១៩នាក់ (ស្រី០៤នាក់) កាណាដា ០៤នាក់(ស្រី០២នាក់) អូស្ត្រាលី០៣នាក់ បារាំង០២នាក់ ប៊ែលហ្ស៊ិក ០១នាក់ បង់ក្លាដេស ០១នាក់ វៀតណាម ០១នាក់ ក្រូអាត ០១នាក់ ទួគី ០១នាក់ និងស៊ែប៊ី ០១នាក់ |
| បុរសបរទេសជាមួយស្រីខ្មែរ | ១៥១នាក់ | |
| សរុប | ១៦០ នាក់ | ១២ សញ្ជាតិ |

**ខ.៣.២. ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស**

❖ ការគ្រប់គ្រងស្ថិតិបច្ចុប្បន្នភាពចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ

អគ្គស្នងការដ្ឋាននគរបាលជាតិ បានតាមដាន និងធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស និងត្រឡប់មកវិញ តាមរយៈការប្រមូលទិន្នន័យពីបណ្តាស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ទូទាំងប្រទេស ដូចមានក្នុងតារាងខាងក្រោម៖

| ប្រចាំខែ | ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស | | | |
|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | |
| | | | សរុប | ស្រី |
| ឧសភា | ១៤១.៩៩៣នាក់ | ៦៣.៧៣៧នាក់ | ៤.១៣៧នាក់ | ១.៣០៣នាក់ |
| ប្រចាំខែ | ទិន្នន័យពលរដ្ឋខ្មែរដែលវិលត្រឡប់ពីក្រៅប្រទេស | | | |
| | សរុប | ស្រី | អនីតិជន | |
| | | | សរុប | ស្រី |
| ឧសភា | ២០.៣០៩នាក់ | ៨.៨០៣នាក់ | ១៩២នាក់ | ១០៥នាក់ |

❖ ការទទួលពលរដ្ឋខ្មែរចំណាកស្រុកដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់

+ <u>ស្ថិតិពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរបរទេសបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែន</u>

| ល.រ | រាជធានី-ខេត្ត | ចំនួនរួម | ស្រី | អនីតិជន | ស្រី |
|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ៩៥៦ | ៣២៦ | | |
| ២ | បាត់ដំបង | ៣០ | ១១ | ០៣ | ០១ |
| ៣ | កោះកុង | ០៥ | ០១ | | |
| | សរុប | ៩៩១ នាក់ | ៣៣៨ នាក់ | ០៣ នាក់ | ០១នាក់ |

+ <u>ការទទួលពលករនៅតាមមណ្ឌលទទួលពលករ</u>

▪ មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងពលករចំណាកស្រុក ដែលបញ្ជូនត្រឡប់ពីប្រទេសថៃ សរុបចំនួន **៧១១**នាក់ (ប្រុស ៣៨៤នាក់ ស្រី ២៣៣នាក់ កុមារ ៤៦នាក់ កុមារី ៤៩នាក់) ក្នុងនោះបានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃចំនួន ០១នាក់(ស្រី) ជាករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម និងពលករចំណាកស្រុក ចំនួន ៧១០នាក់ (ប្រុស ៣៨៣នាក់ ស្រី ២៣២នាក់ កុមារ ៤៦នាក់ កុមារី ៤៩នាក់)។

**ខ.៤. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

❖ ការផ្សព្វផ្សាយ

| ល.រ | ខេត្ត | ទីតាំងផ្សព្វផ្សាយ | កន្លែង/លើក | អ្នកចូលរួម | ស្ត្រី |
|---|---|---|---|---|---|
| ១ | សៀមរាប | -ធ្វើយុទ្ធនាការផ្សព្វផ្សាយ ស្តីពីការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថាន ផលិតផ្ទះ ក្បឿង និងកសិ-ឧស្សាហកម្ម។ | ១៤លើក | ៤៨៧នាក់ | ២៦៤នាក់ |
| ២ | ព្រះវិហារ | -ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ក្នុងវិស័យកសិ-ឧស្សាហកម្ម នៅស្រុកជាំក្សាន្ត និងស្រុកគូលែន។<br>-ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ក្នុងវិស័យឡឥដ្ឋ ក្បឿង និងវិស័យកសិ-ឧស្សាហកម្ម នៅក្នុងស្រុករវៀង ស្រុកជាំក្សាន្ត ស្រុកឆែប និងស្រុកគូលែន។ | ០១លើក<br>១៣សហគ្រាស | ១១៤នាក់<br>៤៣៨នាក់ | ៥០នាក់<br>១៦២នាក់ |
| ៣ | កំពង់ចាម | បានចែកបដា ស្លាកសញ្ញាស្តីពី៖<br>-ការរួមគ្នាប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការងារដោយបង្ខំ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។<br>-ការហាមក្មេងក្រោមអាយុ១៥ឆ្នាំ ចូលក្នុងបរិវេណផលិតកម្ម ឬធ្វើការហាមដាច់ខាតការប្រើប្រាស់ទេសភាពបំណុល ហាមក្មេងធ្វើការពេលយប់ ធ្វើការលើសពី៤ម៉ោង/ថ្ងៃ និងការមិនបញ្ជូនកូនទៅសាលារៀន។ | ៣៩ផ្ទាំង<br>៣៩ផ្ទាំង | | |
| ៤ | កំពង់ឆ្នាំង | -ចុះត្រួតពិនិត្យ និងផ្សព្វផ្សាយ ស្តីពីការបង្ការទប់ស្កាត់ ការប្រើប្រាស់កម្លាំងពលកម្មកុមារនៅសិប្បកម្មផលិតឥដ្ឋ។ | ០៧ទីតាំង | ៧៥នាក់ | ៣១នាក់ |
| ៥ | ក្រចេះ | -ធ្វើយុទ្ធនាការផ្សព្វផ្សាយ ស្តីពីការប្រើប្រាស់ពលកម្មកុមារ នៅកសិ-ឧស្សាហកម្ម។<br>-ផ្សព្វផ្សាយ ស្តីពីការប្រើប្រាស់ពលកម្មកុមារ នៅសិប្បកម្មឡឥដ្ឋ និងក្បឿង។ | ០៣លើក<br>០១លើក | ៤០៦នាក់<br>៣០នាក់ | ១៩០នាក់<br>១៩នាក់ |

❖ **ការធ្វើអធិការកិច្ច**

| ល.រ | ខេត្ត | សកម្មភាព | កន្លែង/លើក | អ្នកចូលរួម | ស្ត្រី |
|---|---|---|---|---|---|
| ១ | កំពង់ឆ្នាំង | -ចុះត្រួតពិនិត្យទីតាំងឡឥដ្ឋ ក្នុងក្រុងកំពង់ឆ្នាំង និងធ្វើកិច្ចសន្យាម្ចាស់អាជីវកម្មមិនឱ្យមានបទល្មើសជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ។ | ០១កន្លែង | ១០នាក់ | ០៦នាក់ |

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

❖ **ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃ អគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួ **២២ករណី** (ប្រៀបធៀបខែមេសា មានចំនួន ២០ករណី កើនឡើង ០២ករណី) ស្មើនឹង ១០% ៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ចំនួន **២៩**នាក់ (ស្រី០៣នាក់) ជនជាតិចិន ចំនួន០៥នាក់។
- សង្គ្រោះជនរងគ្រោះចំនួន ៨១នាក់ (ស្រី៦២នាក់) មានអាយុក្រោម១៥ឆ្នាំ ១១នាក់ អាយុ១៥-១៧ឆ្នាំ ២៥នាក់ និងអាយុ១៨ឆ្នាំឡើង ៤៥នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ៥២នាក់ គ្រួសារ២៩នាក់)។ ក្នុងនោះចែកជា៖

+ ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន **០៥/០៥ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន **០៦**នាក់ ជនជាតិចិន ០២នាក់។ សង្គ្រោះជនរងគ្រោះ **២២**នាក់ (ស្រី០៧នាក់) មានអាយុក្រោម១៥ឆ្នាំ ០១នាក់ អាយុ១៥-១៧ឆ្នាំ ០៤នាក់ និងអាយុ១៨ឆ្នាំឡើង ១៧នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ០៤នាក់ គ្រួសារ ១៨នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ |
|---|---|---|---|---|
| -ការនាំយកអនីតិជន ជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១ | ០១ | | ០២ |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០១ | ០១ | | ១៣ |
| -អំពើលក់ដូរមនុស្ស | ០១ | ០២ | ចិន២ | ០១ |
| -ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០២ | ០២ | | ០៦ |
| សរុប | ០៥ ករណី | ០៦ នាក់ | ០២ នាក់ | ២២ នាក់ |

+ ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន **១៧/១៥ករណី** (កើនឡើង០២ករណី) ឃាត់ខ្លួនជនសង្ស័យ **២៣**នាក់ (ស្រី០៣នាក់) ជនជាតិចិន ០៣នាក់។ សង្គ្រោះជនរងគ្រោះ **៥៩**នាក់ (ស្រី៥៥នាក់) មានអាយុក្រោម១៥ឆ្នាំ ១០នាក់ អាយុ១៥-១៧ឆ្នាំ ២១នាក់ និងអាយុ១៨ឆ្នាំឡើង ២៨នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ៤៨នាក់ គ្រួសារ ១១នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ |
|---|---|---|---|---|
| -ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០១ | ០៥ | ចិន៣ | ០៣ |
| -សញ្ចារកម្ម | ០២ | ០៣ | | ១២ |
| -សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០៣ | ០៤ | | ៣៣ |
| -រូបភាព និងសម្ភារៈអាសអាភាស | ០១ | ០១ | | ០១ |
| -រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ០២ | ០២ | | ០២ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៧ | ០៧ | | ០៧ |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ | | ០១ |
| សរុប | ១៧ ករណី | ២៣ នាក់ | ០៣ នាក់ | ៥៩ នាក់ |

### ឃ. កិច្ចការពារជនរងគ្រោះ

#### ឃ.១. ការទទួល និងសម្ភាសពលករបញ្ជូនទាំងក្នុងប្រទេស និងត្រឡប់ពីក្រៅប្រទេស

ក្រុមការងារការពារជនរងគ្រោះ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត និងអង្គការដៃគូ តាមរយៈនាយកដ្ឋានគាំពារជនរងគ្រោះ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ពីក្រៅប្រទេស សរុបចំនួន ២៦នាក់(ស្រី២២នាក់ កុមារី ០៤នាក់) ប្រទេសចិន ២៥នាក់(ស្រី២១នាក់ កុមារី០៤នាក់) ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ និងប្រទេសថៃ ០១នាក់(ស្រី) ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម។ ក្រោយពីបានកំណត់ អត្តសញ្ញាណដោយមន្ត្រីនគរបាលយុត្តិធម៌ បានរកឃើញជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ២៥នាក់ (ស្រី២១នាក់ កុមារី០៤នាក់)។

#### ឃ.២. ការស្តារនីតិសម្បទា

ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស បានបញ្ជូនទៅស្តារនីតិសម្បទា នៅមជ្ឈមណ្ឌលរបស់អង្គការដៃគូ សរុបចំនួន ២៦នាក់(ស្រី)៖ ទទួលសេវាពីអង្គការការីតាសកម្ពុជា០៤នាក់ អង្គការហាការអន្តរជាតិ ០៤នាក់ អង្គការរតនៈអន្តរជាតិ១៤នាក់ និងអង្គការសម្ព័ន្ធចាប់ដៃ០៤នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការដឹកនាំសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការបណ្តុះបណ្តាល

❖ ការបណ្តុះបណ្តាលក្នុងប្រទេស

| ល.រ | សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | **ខេត្តបន្ទាយមានជ័យ៖**<br>មន្ទីរកិច្ចការនារីខេត្ត<br>-វគ្គបណ្តុះបណ្តាល ស្តីពីភាពជាអ្នកដឹកនាំ និងជំនាញសម្របសម្រួល ទប់ស្កាត់ការជួញដូរមនុស្ស និងស្តីពីអនុវត្តតួនាទីភារកិច្ច គ.ក.ន.ក ទប់ស្កាត់ការជួញដូរមនុស្ស។<br>-សហការជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត បើកវគ្គបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ។ | ០២<br><br>០៤ | ៦៤<br><br>១០២ | ៤១<br><br>៥២ |
| | សរុប | ០៦លើក | ១៦៦នាក់ | ៩៣នាក់ |

❖ ការបណ្តុះបណ្តាលក្រៅប្រទេស

▪ លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បានអញ្ជើញចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល "The International Management of Serious Crime XVIII (IMOSC XVIII) នៅទីក្រុងសេម៉ារ៉ង ប្រទេសឥណ្ឌូនេស៊ី រៀបចំដោយ AFP សហការជាមួយ JCLEC ។ អ្នកចូលរួមជាមន្ត្រីប៉ូលីសចម្រុះស្ថាប័ន មាន ១៤ ប្រទេស៖ អូស្រ្តាលី ទីម័រ ថៃ វៀតណាម ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ស្រីលង្កា ប៉ាពួញ៉ូវហ្គីណេ អារ៉ាប់អេមីរេត កម្ពុជា ញ៉ូវហ្សេលែន ប៉ាគីស្ថាន និងបង់ក្លាដែស។

#### ក.២. សិក្ខាសាលានៅក្នុងប្រទេស

▪ **ខេត្តបន្ទាយមានជ័យ៖** មន្ទីរកិច្ចការនារីខេត្ត បានបើកវគ្គសិក្ខាសាលា ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត ចំនួន ០១លើក អ្នកចូលរួមចំនួន ២១នាក់ (ស្រី ១៩នាក់)។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំ

▪ **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានរៀបចំពិធីបើកការងារសវនកម្មផ្ទៃក្នុង និងកិច្ចប្រជុំចំនួន ០៥លើក អ្នកចូលរួមចំនួន ៩៨នាក់ (ស្រី ២៣នាក់)៖

- ពិធីបើកការងារសវនកម្មផ្ទៃក្នុង សម្រាប់ការិយបរិច្ឆេទ ២០២៤ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅអគ្គលេខាធិការដ្ឋាន នៃគណកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ០១លើក អ្នកចូលរួមចំនួន ៤៩នាក់ (ស្រី ១០នាក់) នៅសាលប្រជុំ នៃទីស្តីការក្រសួងមហាផ្ទៃ។

- កិច្ចប្រជុំពិភាក្សា ជាមួយអង្គការ Asain-Act ស្តីពីសេចក្តីព្រាងក្របខណ្ឌតាមដាន វាយតម្លៃ និងរៀនសូត្រ នៃផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០២៤-២០២៨) ចំនួន ០១លើក អ្នកចូលរួមចំនួន ១៧នាក់ (ស្រី ០៥នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។

- កិច្ចប្រជុំផ្ទៃក្នុងពិភាក្សា ស្តីពីសេចក្តីព្រាងក្របខណ្ឌតាមដាន វាយតម្លៃ និងរៀនសូត្រ នៃផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០២៤-២០២៨) ចំនួន ០២លើក អ្នកចូលរួមចំនួន ១៨នាក់ (ស្រី ០៥នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។

- កិច្ចប្រជុំផ្ទៃក្នុង ត្រៀមបើកកិច្ចសវនកម្ម សម្រាប់ការិយបរិច្ឆេទ ២០២៤ និងបណ្តាឆ្នាំពាក់ព័ន្ធ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចំនួន ០១លើក អ្នកចូលរួមចំនួន ១៤នាក់ (ស្រី ០៣នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។

### ខ.២. ជំនួបពិភាក្សាការងារ

▪ **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានទទួលជួបពិភាក្សាការងារជាមួយប្រតិភូសាធារណៈរដ្ឋឥណ្ឌូនេស៊ី ដឹកនាំដោយ ឧត្តមសេនីយ៍ទោ **ស្លាមិត ហាឌី ស៊ូប្រាប់តូយ៉ូ** តំណាងប្រធានការិយាល័យ វិទ្យាស្ថានអប់រំ និងបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់នគរបាលជាតិឥណ្ឌូនេស៊ី ដើម្បីចែករំលែកបទពិសោធន៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។

▪ **ខេត្តសៀមរាប៖** ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជំនួបពិភាក្សាការងារ ជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងអង្គការមូលនិធិអេ២១ ស្តីពីការរៀបចំផែនការចុះអប់រំផ្សព្វផ្សាយ អំពីការបង្ការទប់ស្កាត់គ្រប់រូបភាព និងការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ដល់សិស្ស និស្សិត នៅតាមសាកលវិទ្យាល័យ វិទ្យាល័យ និងប្រជាពលរដ្ឋ នៅតាមសហគមន៍ ចំនួន ០១លើក។

## គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេស គឺ ៣២លើក មានអ្នកចូលរួមសរុប ៣៥០នាក់(ស្រី ១៥៩នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ២០លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ១២លើក។ (ឧបសម្ព័ន្ធ)

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់យកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយក្នុងចំណោមអាទិភាពនៃផែនការដែលត្រូវយកចិត្តទុកដាក់ គឺជាថាមពលជំរុញចិត្តឱ្យគ្រប់សមាសភាពក្នុងសង្គមទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងដៃគូ ជាតិ និងអន្តរជាតិ ឱ្យរឹតតែប្រឹងប្រែងទ្វេឡើងទៀត

- ច្បាប់ គោលនយោបាយ វិធានការ អនុសាសន៍របស់ប្រមុខដឹកនាំទាំងក្នុងនីតិកាលចាស់ និងថ្មី នៅតែមានគុណតម្លៃសម្រាប់ការអនុវត្ត ជាមូលដ្ឋានបង្អែក និងជាប្រទីបបំភ្លឺផ្លូវសម្រាប់ការកំណត់ការងារជាយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស
- សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត នៅតែមានតម្លៃជាកិច្ចសហប្រតិបត្តិការទូលំទូលាយលើ វិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងអំពើពាក់ព័ន្ធដទៃទៀត
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាកម្លាំងស្នូលក្នុងការអនុវត្តការងារ តាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយក្នុងសង្គមកម្ពុជា
- ការចូលរួមឧបត្ថម្ភគាំទ្រពីអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន និងកិច្ចសហការក្នុងការបំពេញភារកិច្ចតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គឺជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុបសម្រាប់រួមគ្នាធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដ៏មានសក្តានុពល។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម មួយចំនួនដូចជា៖

- ទាមទារការយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបានជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុ សម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗ ចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់
- ត្រូវការពិភាក្សាបន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថា ជនរងគ្រោះ ជនងាយរងគ្រោះ ជនសង្ស័យថារងគ្រោះ... ដែលធ្វើឱ្យការបូកសរុប ទាំងបរិមាណ និងគុណភាព មិនទាន់ស៊ីចង្វាក់គ្នា
- ជនល្មើសមានកលល្បិចជ្រៀតចូលធ្វើសកម្មភាពខុសច្បាប់ និងអូសទាញមនុស្សឱ្យរងគ្រោះជាបន្តបន្ទាប់
- ខ្វះវិធីសាស្ត្រ និងសង្គតិភាពនៃសារអប់រំ ដែលមានប្រសិទ្ធភាព និងអាចបង្ការទប់ស្កាត់បាននូវអំពើជួញដូរ និងកេងប្រវ័ញ្ចគ្រប់ទម្រង់។

## គ. សេចក្តីសន្និដ្ឋាន និងសំណូមពរ

បទល្មើសជួញដូរមនុស្ស និងបទល្មើសដទៃទៀត មានភាពប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ និងរីកសាយឆាប់រហ័ស អាស្រ័យដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបជាមធ្យោបាយសម្រាប់បង្កើនប្រសិទ្ធភាពបទល្មើសឱ្យកាន់តែមានកម្រិតខ្ពស់ និងអាចខ្ពស់ជាងបច្ចេកទេសដែលសមត្ថកិច្ចប្រើប្រាស់បច្ចុប្បន្ន។ ករណីខ្លះ ជនល្មើស និងជនរងគ្រោះ ជាមនុស្សតែមួយ និងមានបណ្តាញប្រទាក់ក្រឡាពីកន្លែងមួយ ទៅកន្លែងមួយ ពីប្រទេសមួយ ទៅប្រទេសមួយ។ ករណីភាគច្រើន មិនពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សទេ តែបង្កប់នូវបទល្មើសផ្សេងទៀត មានជាអាទិ៍ អំពើឆបោក អំពើចាប់ជំរិត គំនុំ ទំនាស់ការងារ ប្រព្រឹត្តខុសច្បាប់ការងារ ខុសច្បាប់អន្តោប្រវេសន៍ ការបន្លំជាជនរងគ្រោះដើម្បីគេចពីសំណាញ់ច្បាប់ ជាដើម។

យុទ្ធសាស្ត្របង្ការទប់ស្កាត់ នៅតែជាអាទិភាព ដែលអាចការពារមិនឱ្យមនុស្សគ្រប់រូបពីដំណាក់កាលដំបូង ដោយមិនរង់ចាំឱ្យដល់ដំណាក់កាលរងគ្រោះ ព្រោះវានឹងធ្វើឱ្យខូចខាត ទាំងធនធានមនុស្ស ធនធានថវិកា ពេលវេលា ទំនាក់ទំនងសង្គម និងការអភិវឌ្ឍន៍គ្រប់វិស័យ។

ការពង្រឹងស្ថាប័ន សមត្ថភាពជំនាញ និងឥរិយាបថមន្ត្រីគ្រប់ឋានានុក្រម និងការពិនិត្យឡើងវិញ នូវនីតិវិធីច្បាប់ ក៏ដូចជាកិច្ចសហការរវាងវិស័យពាក់ព័ន្ធ ប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងជាអន្តរជាតិ នៅតែមានភាពចាំបាច់មិនអាចខ្វះបាន ក្នុងការកាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ។

ជាសំណូមពរ ចំពោះ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងយន្តការនៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

- គប្បីរៀបចំចាត់តាំងមន្ត្រីទទួលខុសត្រូវ បំពេញតាមរចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់ថ្នាក់ឱ្យបានច្បាស់លាស់ ប្រកបដោយការទទួលខុសត្រូវ រួមទាំងមន្ត្រីលេខាធិការដ្ឋានទទួលបន្ទុកការងាររបាយការណ៍ ផែនការ និងការងាររដ្ឋបាល ហិរញ្ញវត្ថុ ដើម្បីងាយស្រួលដល់ការរៀបចំវគ្គបណ្តុះបណ្តាលតាមជំនាញសម្រាប់ការអនុវត្តការងារឱ្យទទួលបានប្រសិទ្ធភាពខ្ពស់
- ពង្រឹងកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្ថាប័ន ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងលេខាធិការដ្ឋានខេត្ត ក្រុង ស្រុក ខណ្ឌ (គ.រ/ខ.ប.ជ) ឱ្យបានទៀងទាត់ប្រចាំខែ ឬត្រីមាស ដើម្បីបូកសរុបរបាយការណ៍ វាយតម្លៃលើសកម្មភាព និងលទ្ធផលនៃការអនុវត្តផែនការតាមយុទ្ធសាស្ត្រនីមួយៗ។

## V. ទិសដៅខែមិថុនា ឆ្នាំ ២០២៥

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួមគឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់

២. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីពង្រឹងកិច្ចសហការចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌

៣. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត

៤. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ

៥. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ នៅតាមបណ្តាក្រសួងស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដាន ការអនុវត្ត

៦. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ

៧. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ

៨. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល

៩. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្នមុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬនៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃសុក្រ ៩កើត ខែអាសាឍ ឆ្នាំ ម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៥

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ ប៊ុនអេង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៣២លើក) មនុស្សចំនួន ៣៥០នាក់ (ស្រី ១៥៩នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម<br>-ជាអធិបតី ក្នុងមិទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៨០ ថ្ងៃកំណើតនគរបាលជាតិកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅបណ្ឌិត្យសភានគរបាលកម្ពុជា។<br>-កិច្ចប្រជុំត្រៀមរបាយការណ៍ គោរពជូន សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការបង្ក្រាបបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម<br>-ក្នុងឱកាសដែល ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុញ្ញាតជូន លោកជំទាវ **រីវ៉ា ប្រាយ** ប្រធានគណៈកម្មាធិការត្រួតពិនិត្យសន្តិសុខ និងសេដ្ឋកិច្ចអាម៉េរិក-ចិន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅសាលទទួលភ្ញៀវអន្តរជាតិ នៃទីស្តីការក្រសួងមហាផ្ទៃ។<br>-ក្នុងជំនួបសម្តែងការគួរសម  និងពិភាក្សាការងារ  ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់  ឯកឧត្តមអភិសន្តិបណ្ឌិត  **ស សុខា**  ឧបនាយករដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាមួយលោកស្រី **ណេលី ហ្កាសាយនី** ប្រធានបេសកកម្ម នៃអង្គការអន្តរជាតិទេសន្តរប្រវេសន៍ នៅសាលទទួលភ្ញៀវអន្តរជាតិ នៃទីស្តីការក្រសួងមហាផ្ទៃ។<br>-កិច្ចប្រជុំពិភាក្សាអំពីវឌ្ឍនភាពការងារ និងបញ្ហាប្រឈម ក្នុងការអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ២០២៣-២០២៤ ក្រោមអធិបតីភាព ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម **ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងប្រតិភូ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ។<br>-កិច្ចប្រជុំពិភាក្សាលើកចុងក្រោយលើផែនការអនុវត្តយុទ្ធសាស្ត្រ  ស្តីពីយុទ្ធនាការគ្រួសាររឹងមាំដើម្បីបញ្ចប់អំពើហិង្សាលើកុមារ  និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់នៅកម្ពុជា ២០២៥-២០២៨ ក្រោមអធិបតីភាព លោកជំទាវ **ញ៉េប សុភាព** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>-កិច្ចប្រជុំពិភាក្សាការងារ ប្រចាំត្រីមាសទី១ ក្រុមការងារយេនឌ័រ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។<br>-សិក្ខាសាលាផ្តល់ព័ត៌មាន ស្តីពីផែនការតាមដាន វាយតម្លៃ និងរៀនសូត្រ ហៅកាត់ថា(MEL) នៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) ក្រោមអធិបតីភាព ឯកឧត្តម **កេង សុម៉ារិទ្ធ** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ នៅសណ្ឋាគារ កាប៉ាវ៉ាន់ រាជធានីភ្នំពេញ។<br>-កិច្ចប្រជុំត្រួតពិនិត្យ ផ្ទៀងផ្ទាត់ផែនការសកម្មភាពបន្ត របស់ក្រុមការងាបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងក្រុមការងារបច្ចេកទេស របស់អង្គការ UNICEF ស្តីពីកម្មវិធីការពារសុវត្ថិភាពកុមារ នៅសាលប្រជុំ គ.ជ.ប.ជ។<br>-ពិធីអបអរសាទរ ខួបលើកទី៧៦ ទិវាកុមារអន្តរជាតិ ១មិថុនា ខួបលើកទី២៤ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៥ ក្រោមអធិបតីភាព ឯកឧត្តម **ជា សុមេធី** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្ប នៅទីស្តីការក្រសួងសង្គមកិច្ច។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** |

| | |
|---|---|
| | -លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ (១៨ច្បាប់) លិខិតចូល (១៨ច្បាប់)<br>-លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ (៣០ច្បាប់) លិខិតចូល (១២ច្បាប់)<br>▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**<br>-ចូលរួមកិច្ចប្រជុំ ស្តីពីក្រុមការងារចំពោះកិច្ច ដើម្បីគ្រប់គ្រង ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យឧក្រិដ្ឋជន ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ។<br>▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**<br>-ចូលរួមកិច្ចប្រជុំពិភាក្សាលើកចុងក្រោយ លើផែនការអនុវត្តយុទ្ធសាស្ត្រ ស្តីពីយុទ្ធនាការគ្រួសាររឹងមាំ ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារ ដោយមិនចាំបាច់នៅកម្ពុជា CAMBODIA PROIECT ២០២៥-២០២៨ នៅសណ្ឋាគារសាន់អេនមួន រាជធានីភ្នំពេញ។<br>-ចូលរួមសិក្ខាសាលាផ្តល់ព័ត៌មាន ស្តីពីផែនការតាមដាន វាយតម្លៃ និងរៀនសូត្រ ហៅកាត់ថា(MEL) នៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) នៅសណ្ឋាគារ កាំាវ៉ាន់ រាជធានីភ្នំពេញ។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**<br>-ចូលរួមកិច្ចប្រជុំគណៈកម្មការប្រឹក្សាគម្រោង ស្តីពីការពិនិត្យវឌ្ឍនភាពឆ្នាំ២០២៤ និងរៀបចំផែនការការងារ សម្រាប់អនុវត្តកម្មវិធី សិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍ (២០២៥-២០២៨) ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ុ វឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសណ្ឋាគារ កាំបូឌីយ៉ាណា។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**<br>-លោកជំទាវ អគ្គលេខាធិការរងទទួលបន្ទុក និងជាប្រធានផែនប្រឆាំងការជួញដូរមនុស្ស នៃក្រុមការងារ SOMTC-កម្ពុជា បានដឹកនាំក្រុមការងារ ពិភាក្សាការងារត្រៀមសម្រាប់សិក្ខាសាលាបូកសរុប និងផ្សព្វផ្សាយលទ្ធផលការងាររបស់ក្រុមការងារSOMTC-កម្ពុជាឆ្នាំ២០២៤ និងលើកទិសដៅឆ្នាំ២០២៥ នៅក្រសួងមហាផ្ទៃ។<br>-រៀបចំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការរៀនបញ្ហា និងគ្រប់គ្រងម៉ាស៊ីនរបស់ការិយាល័យស្រាវជ្រាវព័ត៌មាន និងត្រួតពិនិត្យ។<br>-ចូលរួមកិច្ចប្រជុំ ក្រុមការងារឧក្រិដ្ឋកម្មឆ្លងដែន ស្តីពីការជួញដូរមនុស្សលើកទី២១ តាមរយៈប្រព័ន្ធវីដេអូ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>-រៀបកិច្ចប្រជុំ ស្តីពីការណែនាំអំពីរចនាសម្ព័ន្ធរបស់ គ.ជ.ប.ជ និងការធ្វើបទបង្ហាញខ្លី ស្តីពីការប្រើប្រាស់បណ្ណាល័យវីគី ដល់មន្ត្រីថ្មី នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>-ចូលរួមកិច្ចប្រជុំផ្ទៃក្នុង សម្រាប់ត្រៀមសិក្ខាសាលាបូកសរុប និងផ្សព្វផ្សាយលទ្ធផលការងារ របស់ក្រុមការងារ SOMTC-កម្ពុជា ឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>-ចូលរួមសិក្ខាសាលា ផ្សព្វផ្សាយក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ និងប្រកាសអន្តរក្រសួង ស្តីពីការពង្រីកវិសាលភាពនៃការអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល សម្រាប់សមាជិក ប.ស.ស ជាមន្ត្រីមានផ្ទៃពោះនិងកុមារ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ១២លើក អ្នកចូលរួមសរុបចំនួន ៣៥០នាក់ (ស្រី ១៥៩នាក់)** | |
| **ខេត្តសៀមរាប** | -លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា ចំនួន០១លើក អ្នកចូលរួមចំនួន ៦៥នាក់ ស្រី៣៦នាក់។<br>-ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំ ចំនួន១០លើក អ្នកចូលរួមចំនួន២៦៥នាក់ ស្រី១១៥នាក់។ |
| **ខេត្តព្រះវិហារ** | -លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា ចំនួន០១លើក អ្នកចូលរួមចំនួន១៦នាក់ ស្រី០៤នាក់។ |